របាយការណ៍ព័ត៌មានអំពីវ៉ាក់សាំង

វ៉ាក់សាំង Hib

អ្វីដែលអ្នកត្រូវដឹង

[*Haemophilus Influenzae* Type b (ជម្ងឺគ្រុនដោយសារមេរោគឆ្លងប្រភេទ b)]

មានរបាយការណ៍ព័ត៌មានអំពីវ៉ាក់សាំងជាច្រើនជាភាសាអេស្ប៉ាញ និងភាសាផ្សេងៗទៀត។ សូមចូលទៅកាន់គេហទំព័រ www.immunize.org/vis។

1 ហេតុអ្វីត្រូវចាក់វ៉ាក់សាំង?

ជម្ងឺគ្រុនដោយសារមេរោគឆ្លង ប្រភេទ b *(Haemophilus influenzae* type b - Hib) គឺជាជម្ងឺដ៏ធ្ងន់ធ្ងរមួយដែលបង្កដោយពពួកបាក់តេរី។ ជាទូទៅ វាវាយប្រហារលើក្មេងៗមានអាយុក្រោម 5 ឆ្នាំ។

កូនៗរបស់អ្នកអាចកើតជម្ងឺ Hib តាមរយៈក្មេងៗ ឬមនុស្សពេញវ័យដទៃទៀតនៅជុំវិញខ្លួនរបស់គេ ដែលមានបាក់តេរី ហើយមិនបានដឹងពីបញ្ហានោះ។ មេរោគទាំងនោះឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ ប្រសិនបើមេរោគមាននៅក្នុងច្រមុះ និងករបស់ក្មេង ក្មេងនោះអាចនឹងមិនឈឺទេ។ ប៉ុន្តែពេលខ្លះ មេរោគចូលទៅដល់សួត ឬសរសៃឈាម ហើយបន្ទាប់មក Hib អាចបង្កជាបញ្ហាធ្ងន់ធ្ងរផ្សេងៗ។

នៅមុនពេលទទួលបានវ៉ាក់សាំង Hib ជម្ងឺ Hib គឺជាអ្នកបង្កឲ្យមានមេរោគលោកស្រោមខូរចំពោះកុមារមានអាយុក្រោម 5ឆ្នាំ នៅសហរដ្ឋអាមេរិក។ ជម្ងឺរលាយស្រោមខូរគឺជាការឆ្លងមេរោគនៃសរសៃក្នុងខូរក្បាល និងខូរឆ្អឹងខ្នង។ វាអាចបណ្តាលជាការបំផ្លាញខូរក្បាល និងជម្ងឺថ្លង់។ ជម្ងឺ Hib ក៏អាចបង្កឲ្យមាន៖

- ជម្ងឺរលាតសូរ
- ហើមបំពង់កខ្លាំង ធ្វើឲ្យពិបាកដកដង្ហើម
- ឆ្លងមេរោគចូលក្នុងឈាម សន្លាក់ ឆ្អឹង និងស្រោមបេះដូង
- ការប៉ះពាល់ដល់អាយុជីវិត

ជារៀងរាល់ឆ្នាំ នៅមុនពេលចាក់វ៉ាក់សាំង Hib ក្មេងៗមានអាយុក្រោម 5ឆ្នាំប្រហែល 20 000 នាក់នៅសហរដ្ឋអាមេរិក មានជម្ងឺ Hib ដែលគម្រាមដល់អាយុជីវិត ហើយប្រហែល 3% – 6% នៃពួកគេទាំងនោះបានបាត់បង់ជីវិត។

វ៉ាក់សាំង Hib អាចការពារជម្ងឺ Hib បាន។ ចាប់តាំងពីមានវ៉ាក់សាំង Hib ករណីរាតត្បាតនៃជម្ងឺ Hib បានធ្លាក់ចុះជាង 99%។ ក្មេងច្រើននាក់ទៀតអាចកើតជម្ងឺ Hib ប្រសិនបើយើងបញ្ឈប់ការចាក់វ៉ាក់សាំងនេះ។

2 វ៉ាក់សាំង Hib

មានវ៉ាក់សាំង Hib ប៉ុន្មានម៉ាកខុសៗគ្នា។ កូនរបស់អ្នកនឹងទទួលបានវ៉ាក់សាំងក្នុងបរិមាណ 3 ឬ 4 អាស្រ័យទៅតាមម៉ាកវ៉ាក់សាំងដែលប្រើ។

ជាទូទៅ បរិមាណវ៉ាក់សាំង Hib ត្រូវបានណែនាំទៅតាមអាយុដូចខាងក្រោម៖

- បរិមាណលើកទី 1៖ អាយុ 2 ខែ
- បរិមាណលើកទី 2៖ អាយុ 4 ខែ
- បរិមាណលើកទី 3៖ អាយុ 6 ខែ (ប្រសិនបើត្រូវការអាស្រ័យទៅតាមម៉ាកវ៉ាក់សាំង)
- បរិមាណលើកចុងក្រោយ៖ អាយុ 12–15 ខែ

គេអាចផ្តល់វ៉ាក់សាំង Hib ស្របពេលជាមួយវ៉ាក់សាំងផ្សេងៗទៀតបានដោយសុវត្ថិភាព។

គេអាចផ្តល់វ៉ាក់សាំង Hib ជាផ្នែកនៃការចាក់វ៉ាក់សាក់រួមគ្នាបាន។ ការចាក់វ៉ាក់សាក់រួមគ្នាត្រូវបានធ្វើឡើងនៅពេលគេបញ្ចូលវ៉ាក់សាំងចំនួនពីរឬច្រើនប្រភេទចូលគ្នាតែមួយ ដើម្បីធ្វើឲ្យការចាក់វ៉ាក់សាំងមួយអាចការពារជម្ងឺច្រើនជាងមួយ។ សូមសាកសួរវេជ្ជបណ្ឌិតរបស់អ្នកដើម្បីទទួលបានព័ត៌មានបន្ថែម។

ជាធម្មតា អ្នកមានអាយុលើសពី 5ឆ្នាំ ពុំត្រូវការវ៉ាក់សាំង Hib ទេ។ ប៉ុន្តែវាអាចត្រូវផ្តល់ឲ្យក្មេងមានអាយុច្រើនជាងនេះ ឬមនុស្សពេញវ័យមុនពេលធ្វើការវះកាត់យកសរីរាង្គបន្សុទ្ធឈាមចេញ ឬការបណ្តុះខូរឆ្អឹង។ វាក៏អាចត្រូវផ្តល់ឲ្យបុគ្គលដែលមានបញ្ហាសុខភាពដូចជាជម្ងឺឆ្លងពីឪពុកម្តាយទៅកូន ឬជម្ងឺ HIV/AIDS។ សូមសាកសួរវេជ្ជបណ្ឌិតរបស់អ្នកដើម្បីទទួលបានព័ត៌មានលម្អិត។

3 បុគ្គលមួយចំនួនមិនគួរចាក់វ៉ាក់សាំងនេះទេ

មិនគួរផ្តល់វ៉ាក់សាំង Hib ទៅក្មេងមានអាយុតិចជាង 6 សប្តាហ៍ទេ។

សូមប្រាប់វេជ្ជបណ្ឌិតរបស់អ្នក៖

- **ប្រសិនបើអ្នកជម្ងឺមានប្រតិកម្មខ្លាំង (គម្រាមដល់អាយុជីវិត)។** ប្រសិនបើអ្នកជម្ងឺធ្លាប់មានប្រតិកម្មខ្លាំងគម្រាមដល់អាយុជីវិតបន្ទាប់ពីចាក់វ៉ាក់សាំងក្នុងបរិមាណមួយ ឬមានប្រតិកម្មខ្លាំងចំពោះផ្នែកណាមួយនៃវ៉ាក់សាំងនេះ គាត់មិនគួរចាក់ទេ។
- **ប្រសិនបើអ្នកជម្ងឺមានអារម្មណ៍មិនស្រួល។** វេជ្ជបណ្ឌិតរបស់អ្នកអាចនឹងស្នើឲ្យរង់ចាំរហូតដល់អ្នកជម្ងឺមានអារម្មណ៍ប្រសើរឡើង។ ប៉ុន្តែអ្នកគួរតែត្រឡប់មកវិញ។

U.S. Department of Health and Human Services
Centers for Disease Control and Prevention

4 គ្រោះថ្នាក់ផ្សេងៗពីប្រតិកម្មវ៉ាក់សាំង

ការចាក់វ៉ាក់សាំងក៏ដូចជាការប្រើថ្នាំដែរ ពោលគឺអាចផ្តល់ផលអវិជ្ជមានផ្សេងៗ។ ជាធម្មតា បញ្ហាទាំងនេះពុំមានសភាពធ្ងន់ធ្ងរទេ ហើយនឹងបាត់ទៅវិញដោយខ្លួនឯង។

ផលអវិជ្ជមានមួយចំនួនក៏អាចកើតមានដែរ ប៉ុន្តែកម្រណាស់។

បុគ្គលភាគច្រើនដែលទទួលបានវ៉ាក់សាំង Hib ពុំមានបញ្ហាជាមួយវាទេ។

បញ្ហាមិនធ្ងន់ធ្ងរ បន្ទាប់ពីទទួលបាន Hib៖

- ឡើងក្រហម ក្តៅ ឬហើមត្រង់កន្លែងចាក់វ៉ាក់សាំង
- គ្រុនក្តៅ

បញ្ហាទាំងនេះគឺមិនប្រក្រតីទេ។ ប្រសិនបើពួកវាកើតឡើង ជាធម្មតាគឺភ្លាមៗ បន្ទាប់ពីចាក់វ៉ាក់សាំង និងមានរយៈពេល 2 ឬ 3 ថ្ងៃ។

បញ្ហាផ្សេងៗដែលអាចកើតមានបន្ទាប់ពីចាក់វ៉ាក់សាំងណាមួយ៖

- អាចសន្លប់រយៈពេលខ្លីបន្ទាប់ពីមានប្រតិបត្តិការវេជ្ជសាស្ត្រដូចជាការចាក់វ៉ាក់សាំងនេះជាដើម។ ការអង្គុយ ឬសម្រាកប្រមាណ 15នាទី អាចជួយទប់ស្កាត់ការសន្លប់ និងការរងរបួសដោយសារការដួលបាន។ សូមប្រាប់វេជ្ជបណ្ឌិតរបស់អ្នកប្រសិនបើអ្នកមានអារម្មណ៍ធីងធោង ឬប្តូរការយល់ឃើញ ឬឮសំឡេងចេញពីក្នុងត្រចៀក។
- អាចឈឺស្មាខ្លាំង និងលែងសូវមានរំញោចនៅដៃបន្ទាប់ពីចាក់វ៉ាក់សាំង ប៉ុន្តែវាជាករណីកម្រណាស់។
- ប្រតិកម្មធ្ងន់ធ្ងរពីវ៉ាក់សាំងកម្រកើតមានណាស់ ពោលគឺត្រូវបានប៉ាន់ប្រមាណថាតិចជាង 1 ក្នុងការចាក់ចំនួនមួយលាន។ ប្រសិនបើករណីមួយនោះអាចកើតមាន វានឹងកើតក្នុងរយៈពេលពីរបីនាទីទៅពីរបីម៉ោងបន្ទាប់ពីចាក់វ៉ាក់សាំងរួច។

សុវត្ថិភាពរបស់វ៉ាក់សាំងគឺតែងតែត្រូវបានត្រួតពិនិត្យ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ៖**www.cdc.gov/vaccinesafety/**

5 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរវិញ?

តើខ្ញុំគួរពិនិត្យមើលអ្វី?

- ពិនិត្យមើលអ្វីដែលបង្កជាកង្វល់ដល់អ្នកដូចជាសញ្ញាប្រតិកម្មខ្លាំង គ្រុនខ្លាំង ឬប្តូរឥរិយាបថ។
  សញ្ញាប្រតិកម្មខ្លាំងអាចមានដូចជាបន្ទាលត្រអាក ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងលោតញាប់ ធីងធោង និងចុះខ្សោយកម្លាំង។ សញ្ញាទាំងនេះអាចកើតមានក្នុងរយៈពេលពីរបីនាទីទៅពីរបីម៉ោងបន្ទាប់ពីចាក់វ៉ាក់សាំងរួច។

តើខ្ញុំគួរធ្វើអ្វី?

- ប្រសិនបើអ្នកយល់ថា វាគឺជាប្រតិកម្មខ្លាំង ឬករណីបន្ទាន់ដែលមិនអាចរង់ចាំបាន សូមហៅទូរស័ព្ទតាមរយៈលេខ 9-1-1 ឬនាំបុគ្គលនោះទៅកាន់មន្ទីរពេទ្យដែលនៅក្បែរបំផុត។ បើមិនដូច្នោះទេ សូមទាក់ទងទៅវេជ្ជបណ្ឌិតរបស់អ្នក។
- បន្ទាប់មកទៀត សូមរាយការណ៍ពីករណីប្រតិកម្មនោះទៅប្រព័ន្ធរាយការណ៍ពីបញ្ហាវ៉ាក់សាំង (Vaccine Adverse Event Reporting System - VAERS)។ វេជ្ជបណ្ឌិតរបស់អ្នកនឹងរៀបចំរបាយការណ៍នេះទុក ឬអ្នកអាចធ្វើដោយខ្លួនឯងបានតាមរយៈគេហទំព័ររបស់ VAERS គឺ **www.vaers. hhs.gov** ឬហៅទូរស័ព្ទទៅលេខ **1-800-822-7967**។

VAERS គឺសម្រាប់តែការរាយការណ៍ពីប្រតិកម្មប៉ុណ្ណោះ។ វាមិនផ្តល់ដំបូន្មានផ្នែកវេជ្ជសាស្ត្រជូនអ្នកទេ។

6 កម្មវិធីសំណងលើការរងរបួសពីការចាក់វ៉ាក់សាំងថ្នាក់ជាតិ

កម្មវិធីសំណងលើការរងរបួសពីការចាក់វ៉ាក់សាំងថ្នាក់ជាតិ (National Vaccine Injury Compensation Program - VICP) គឺជាកម្មវិធីសហព័ន្ធដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់សំណងដល់បុគ្គលដែលរងរបួសដោយសារប្រភេទវ៉ាក់សាំងជាក់លាក់មួយចំនួន។

បុគ្គលដែលយល់ថាពួកគេរងរបួសដោយសារវ៉ាក់សាំងអាចស្វែងយល់អំពីកម្មវិធី និងការដាក់បណ្តឹងតាមរយៈការហៅទូរស័ព្ទទៅកាន់លេខ **1-800-338-2382** ឬចូលទៅកាន់គេហទំព័ររបស់ VICP គឺ **www.hrsa.gov/vaccinecompensation**។

7 តើខ្ញុំអាចស្វែងយល់បន្ថែមដោយរបៀបណា?

- សាកសួរវេជ្ជបណ្ឌិតរបស់អ្នក។ 1–888–767–4687
- ហៅទូរស័ព្ទទៅក្រសួងសុខាភិបាលក្នុងតំបន់ ឬដ្ឋរបស់អ្នក។
- ទាក់ទងមជ្ឈមណ្ឌលត្រួតពិនិត្យ និងបង្ការជម្ងឺ (Centers for Disease Control and Prevention (CDC))៖
  - ហៅទូរស័ព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)**
  - ចូលទៅកាន់គេហទំព័ររបស់ CDC គឺ **www.cdc.gov/vaccines**

Vaccine Information Statement (Interim)

Hib Vaccine

Cambodian

2/04/2014

Office Use Only

42 U.S.C. § 300aa-26

Translation provided by the California Department of Public Health

DCH–0449CA
AUTH: P.H.S., Act 42, Sect. 2126.

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវពត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណាត្រឹមត្រូវ, ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត, ពត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនពត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។